រឿងខ្លី

# កាបូបលុយ

និពន្ធដោយ សុខ ចាន់ផល
H/P : 092 48 25 78

មិត្តភក្តិទូរស័ព្ទមកតឿនខ្ញុំឱ្យស្រួតទៅជួបជុំជប់លៀងជាមួយពួកគេ។ ពេលបើកឡានចេញពីកន្លែងធ្វើការ ខ្ញុំឃើញជនរងគ្រោះម្នាក់ឈាមស្រោចជោកខ្លួន ដេកស្ដូកស្ដឹងនៅនឹងមាត់ផ្លូវចូលមន្ទីរពេទ្យ។ ឃើញខ្ញុំបើកកញ្ចក់ឡាន មីងម្នាក់ស្រែកប្រាប់ខ្ញុំ "លោកគ្រូពេទ្យ ជួយមើលគាត់ផង! គាត់ត្រូវឡានបុកធ្ងន់ណាស់ តែម្ចាស់ឡានរត់បាត់ស្រមោលហើយ។"

ខ្ញុំសម្លឹងមើលជនរងគ្រោះនោះម្ដងទៀត មុននឹងបិទកញ្ចក់បើកឡានចេញទៅ។ គេថាមានតែអ្នកក្រនោះទេ ដែលដឹងសុខទុក្ខអ្នកក្រដូចគ្នា។ តួយ៉ាងដូចស្ថានភាពនេះ មនុស្សបីបួននាក់ដែលខ្វល់នឹងជនសន្លប់នោះសុទ្ធសឹងតែជាអ្នកក្រ ដែលរស់នៅមុំមន្ទីរពេទ្យ។ តាមមើលទៅអ្នករងគ្រោះនោះប្រហែលជាតាចាស់សុំទាន ដើរធ្វើពុតជាខ្វាក់ភ្នែក បាបកម្មក៏ត្រូវគេបុកឱ្យរាងចាល។

ខ្ញុំចតឡានស្រួលបួល រួចដើរចូលទៅក្នុងសួនរាត្រី។ ឆាកជីវិតដ៏សែនខ្លី តើមនុស្សត្រូវស្វែងរកន័យអ្វីឱ្យខ្លួនឯង? ការងារជាវេជ្ជបណ្ឌិត អត្ថន័យវដ្ដសង្សារនៅជិតខ្ញុំបង្កើយ។ នៅក្នុងមន្ទីរពេទ្យតែមួយ ទារកដែលទើបនឹងកើតដំណាលគ្នានឹងចាស់ជរាដែលស្លាប់ទៅវិញ។ មានតែការសោយសុខទេ ទើបជាការងារពិតប្រាកដរបស់មនុស្ស។ ក្រេបស្រាដ៏ឈ្ងុយ អង្គុយកៀកកើយនារីដ៏ស្រស់សោភា តើអ្នកណាថាទេវតានៅលើមេឃសប្បាយជាងមនុស្ស?

"លោកពូ! ជ្រុះកាបូបលុយហើយ!"

ខ្ញុំងាកទៅឃើញក្មេងស្រីលក់ផ្កាម្លិះម្នាក់ រត់យកកាបូបលុយមកហុចឱ្យខ្ញុំ។ ខ្ញុំសម្លឹងមុខវា រួចយកកាបូបលុយរបស់ខ្ញុំមកមើល។ ក្មេងស្រីនោះក៏ស្រាប់តែដើររុយទៅវិញ ធ្វើឱ្យខ្ញុំទៅជាឆ្ងល់នឹងអាកប្បកិរិយានេះ។

"ឈប់សិន!"

ក្មេងស្រីងាកមក ព្រមទាំងសួរខ្ញុំ "ពូចង់ទិញផ្កាអេះ?"

ខ្ញុំងក់ក្បាល ទើបវាដើរមកវិញ។ ខ្ញុំនៅតែសម្លឹងមើលវាគ្មានប្រិច មិនខ្វល់នឹងស្ដាប់តម្លៃផ្កាម្លិះទេ ព្រោះខ្ញុំចង់ស្ដាប់អារម្មណ៍របស់វាប៉ុណ្ណោះ។ ខ្ញុំសួរវាថា "ហេតុអ្វីឯងមិនយកកាបូបលុយខ្ញុំរត់ទៅផ្ទះទៅ?"

វាហាក់ឆ្ងល់នឹងសំណួរខ្ញុំ "ព្រោះវាជារបស់ពូ!"

"ឯងដឹងថានៅក្នុងកាបូបលុយនេះមានប្រាក់ប៉ុន្មានទេ?"

វាគ្រវីក្បាល។

"ប្រាក់ក្នុងកាបូបនេះអាចឱ្យឯងឈប់ដើរលក់ផ្កាបានប្រហែលមួយឆ្នាំ។"

វាសម្លឹងមុខខ្ញុំភ្លឹះៗ ទើបខ្ញុំថាឱ្យវា "តើឯងកំពុងស្ដាយមែនទេ?"

"អត់ទេ! ខ្ញុំចូលចិត្តដើរលក់ផ្កា អត់ចង់ឈប់លក់ផ្កាផង!"

ខ្ញុំហាក់ដូចជាចង់សើចបន្តិចយំបន្តិច ហួសចិត្តនឹងក្មេងស្រីដ៏ល្ងង់ខ្លៅនេះ។ រួចខ្ញុំហូតលុយពីកាបូបប្រាំម៉ឺនរៀលហុចឱ្យទៅវា។

"ផ្កាខ្ញុំមួយភួងតែមួយពាន់រៀលទេ!"

"យកទៅ ពូឱ្យឯង!" ខ្ញុំប្រាប់វា។

"តែ... ពុកម៉ែខ្ញុំមិនឱ្យយកប្រាក់អ្នកណាទទេៗឡើយ។"

"ជាប្រាក់សងគុណឯង ដែលរើសកាបូបលុយឱ្យពូ។"

ក្មេងស្រីបែរជាគ្រវីក្បាល "គ្រាន់តែរើសកាបូបលុយជូនពូប៉ុណ្ណឹង មិនលំបាកអីផង ហេតុអីត្រូវបានលុយសងគុណ? ពុកម៉ែខ្ញុំប្រាប់ថា ធ្វើមនុស្សត្រូវចេះជួយគ្នាទៅវិញទៅមក ទើបរស់នៅបានសប្បាយចិត្តទាំងអស់គ្នា។"

ខ្ញុំសើចរលាក់តិចៗដាក់វា "តើអ្នកណាគឺជាពុកម៉ែរបស់ឯង? ពួកគាត់គឺជាលោកសង្ឃ និងដូនជីអ្ហែ?

"ពុកខ្ញុំជាកម្មករសំណង់ ម៉ែខ្ញុំលក់បន្លែនៅផ្សារ។"

ខ្ញុំនៅស្ងៀមទ្រឹង ព្រោះខួរក្បាលដូចជាច្របូកច្របល់នឹងពាក្យមួយម៉ាត់ៗរបស់ក្មេងស្រីនេះ។ ឃើញសភាពខ្ញុំ វាក៏ប្រាប់ខ្ញុំទៀត "ពុកម៉ែខ្ញុំតែងតែប្រាប់ខ្ញុំថា ជួយគ្នាគឺជារឿងធម្មតារបស់មនុស្ស។ ខ្ញុំសប្បាយចិត្តណាស់ដែលអាចជួយរើសកាបូបលុយជូនពូ ព្រោះបើពូបាត់កាបូបលុយ ពូនឹងស្ដាយមិនសប្បាយចិត្ត។ ពុកម៉ែខ្ញុំឱ្យចេះយកចិត្តគេប្រៀបនឹងចិត្តខ្លួនឯង ហើយត្រូវជួយអ្នកដទៃឱ្យដូចជួយខ្លួនឯង។"

ពិតជាល្ងង់ បង្រៀនកូនឱ្យល្ងង់មែន! ខ្ញុំបញ្ចើចឱ្យវាថា "ពុកម៉ែឯងតែងតែប្រដៅទៀតថា ធ្វើល្អបានល្អមែនទេ?"

"ចាស! ពុកម៉ែខ្ញុំថា មនុស្សតែងតែដណ្ដើមគ្នាធ្វើអំពើអាក្រក់ មិនសូវមានអ្នកដណ្ដើមគ្នាធ្វើអំពើល្អឡើយ។ តាមពិតធ្វើអំពើល្អគ្មានអីលំបាកទេ។"

ក្មេងស្រីនេះនិយាយគ្រប់ម៉ាត់សុទ្ធតែពាក្យម៉ែឪវា ខ្ញុំក៏សួរម៉ែឪវាតាមរយៈវាថា "ចុះកន្លងមកគ្រួសារឯងធ្វើអំពើល្អ បានផលល្អអីខ្លះហើយ?"

"មិនឃើញបានអីផង!"

ខ្ញុំសើចខឹក១ "ក្រែងថាធ្វើល្អបានល្អអ្ហេះ?"

"ពុកម៉ែខ្ញុំថា បើធ្វើល្អចង់បានផល មិនមែនមានន័យថាធ្វើល្អទេ!"

ខ្ញុំនៅទ្រឹងជាលើកទីពីរ គិតថាគ្រួសារពិតជាសាលារៀនទីមួយរបស់មនុស្សមែន។ កម្មករសំណង់ និងអ្នកលក់បន្លែ មានន័យថាជាមនុស្សបរាជ័យបាត់ទៅហើយ ឬក៏ពួកគេចង់ឱ្យកូនដើរតាមគន្លងរបស់ខ្លួន? ឃើញខ្ញុំនៅស្ងៀម ក្មេងស្រីនោះប្រុងដើរចេញ តែខ្ញុំឃាត់វាសួរទៀត "តើថ្ងៃក្រោយឯងចង់ធ្វើការអី ឬក៏ចង់ដើរលក់ផ្ការរហូត?"

វាគិតបន្តិចទើបឆ្លើយ "ពុកម៉ែខ្ញុំប្រាប់ថា ការងារអីក៏ល្អដែរ ឱ្យតែមនុស្សចេះឱ្យតម្លៃ។ ពុកជាកម្មករសំណង់សង់ផ្ទះឱ្យមនុស្សនៅ ម៉ែគឺជាអ្នកលក់បន្លែឱ្យគេយកទៅធ្វើម្ហូប ឯខ្ញុំក្រៅពីទៅរៀនក៏ដើរលក់ផ្កាគ្រាន់បានប្រាក់ចំណេញបន្ថែមជួយពួកគាត់។"

មនុស្សល្អតែងត្រូវមនុស្សអាក្រក់ធ្វើបាប មនុស្សដូចជាពុកម៉ែក្មេងនេះប្រាកដជាត្រូវគេធ្វើបាបរហូតក្លាយជាមនុស្សកំសាកអស់ទៅហើយ។ ខ្ញុំសួរវាទៀតថា "តើពួកឯងមិនដែលចង់បានទ្រព្យសម្បត្តិទេ មែនទេ?"

"ពុកម៉ែខ្ញុំធ្លាប់ប្រាប់ខ្ញុំថា ទ្រព្យសម្បត្តិចាំបាច់ជាងគេគឺគុណធម៌។ រស់នៅត្រូវរៀនឱ្យខ្លួនឯងមានគុណធម៌។"

គុណធម៌ពេកទើបមួយជាតិនៅតែក្ររហាម។ ក្មេងស្រីក៏ដើរចេញពីខ្ញុំ ទៅលក់ផ្ការបស់វាបន្ត។ វាប្រាកដជាគិតរហូត ក្រែងអាចធ្វើអំពើល្អលើអ្នកណាម្នាក់ ដើម្បីប្រាប់ឱ្យម៉ែឪវាសប្បាយចិត្ត។ ពិតចំជាមនុស្សម្នាក់ក្នុងមួយលាននាក់មែន! ហ៊ឹះ!... ហាស! ហាស! កម្មករមានគុណធម៌អីចឹងតើ បាននៅតែកម្មករ!... ខ្ញុំសប្បាយចិត្តណាស់ ដែលអាចជួយរើសកាបូបលុយជូនពូ... មនុស្សតែងដណ្ដើមគ្នាធ្វើអំពើអាក្រក់... ធ្វើអំពើល្អចង់បានផល មិនមែនមានន័យថាធ្វើល្អទេ... រស់នៅត្រូវរៀនឱ្យខ្លួនឯងមានគុណធម៌... ហាស! ហាស!... ការងារអីក៏មានតម្លៃដែរ សូម្បីតែអ្នកលក់បន្លែ... ទម្រាំខ្ញុំជាវេជ្ជបណ្ឌិត... ហាស!...

ខ្ញុំនឹកឃើញសើច១។ មិននឹកស្មានថា ព្រោះតែពាក្យរបស់ក្មេងស្រីលក់ផ្កាម្នាក់ ធ្វើឱ្យខ្ញុំដើរលែងចង់ទៅមុខ រហូតដល់ឈប់ធ្មឹង សម្លឹងទៅរកទីកន្លែងដែលខ្ញុំធ្លាប់តែរកន័យឱ្យជីវិត។ មិត្តភក្តិខ្ញុំប្រាកដជាកំពុងអន្ទះសាចាំផ្លូវខ្ញុំ។ សំណើចក្អាកក្អាយក៏នឹងត្រៀមសើចឱ្យអស់រឿងសៅហ្មងក្នុងចិត្ត។ ប៉ុន្តែ... ខ្ញុំស្រាប់តែរត់ត្រឡប់ក្រោយវិញ។ ខ្ញុំបើកឡានយ៉ាងលឿនសំដៅទៅមន្ទីរពេទ្យ។ ជនគ្រោះថ្នាក់ចរាចរណ៍នោះនៅតែដេកស្រោចឈាម គ្មានអ្នកណារវីរវល់ដដែល។ គ្រូពេទ្យទាំងអស់ពិតជាដណ្ដើមគ្នាធ្វើអាក្រក់មែន! តើអ្នកណាល្ងង់ដូចក្មេងស្រី ដែលរើសកាបូបលុយឱ្យខ្ញុំទទេ១នោះ?

ខ្ញុំប្រាប់ឱ្យគ្រូពេទ្យប្រញាប់រៀបចំការវះកាត់ឱ្យជនរងគ្រោះជាបន្ទាន់។ ពួកគេប្រាកដជាឆ្ងល់ថា តើនឹងទៅយកប្រាក់ព្យាបាលពីអ្នកណា? រួចក៏ធ្វើតាមខ្ញុំទាំងចុងដៃចុងជើង។ ខ្ញុំចាប់ផ្ដើមវះកាត់ជើងរបស់ជនរងគ្រោះ ដើម្បីឱ្យថ្ងៃក្រោយគេអាចដើរបានដូចជាខ្ញុំដែរ។ អារម្មណ៍ធ្វើការម្ដងនេះគឺស្ងប់ស្រស់ថ្លា ប្រហែលជាបានមកពីក្ដីប្រាថ្នាជួយគេទេដឹង? ខ្ញុំនៅតែនឹកឃើញពាក្យសម្ដីរបស់ក្មេងស្រីលក់ផ្កា ហើយក៏ជ្រួតជ្រាបម្ដងបន្តិច១។

ទីបំផុតការវះកាត់ទទួលជោគជ័យល្អណាស់។ វាគឺជាលើកទីមួយដែលខ្ញុំសប្បាយចិត្តនឹងការងារដល់ថ្នាក់នេះ។ មនសិការវិជ្ជាជីវៈខ្ញុំចាំច្បាស់ណាស់ ប៉ុន្តែទើបតែយល់នៅពេលនេះឯង។ ខ្ញុំស្រមៃឃើញសាច់ញាតិរបស់ជនរងគ្រោះ ដែលត្រេកអរព្រោះប្ដី ឪពុក ឬបងប្រុសរបស់ពួកគេអាចរស់ជួបជុំពួកគេបន្តទៀត។ ឱ! នេះហើយគឺជារឿងសប្បាយពិតប្រាកដរបស់ខ្ញុំ!

ខ្ញុំបើកឡានទៅផ្ទះសម្រាក ក៏ស្រាប់តែក្រឡេកឃើញក្មេងស្រីលក់ផ្កាកំពុងដើរជាមួយស្ត្រីចំណាស់ម្នាក់ ទំនងជាម្ដាយរបស់វា។ ខ្ញុំឈប់ឡាន ដើរចេញទៅរកវា "អេ! ឯងដើរទៅណាហ្នឹង?"

ក្មេងស្រីនិងម្ដាយវាសម្លឹងមុខគ្នាស្ទើរតែស្រក់ទឹកភ្នែក ទើបប្រាប់ខ្ញុំថា "ពុកខ្ញុំបាត់តាំងពីល្ងាច មិនឃើញគាត់ត្រឡប់ទៅផ្ទះសោះ! ពួកខ្ញុំបារម្ភថាគាត់ខ្យល់គរ ឬគ្រោះថ្នាក់នៅតាមផ្លូវ..."

ខ្ញុំភ្ញាក់ព្រើត រួចក៏ជូនពួកគេទៅមើលអ្នកជំងឺដែលខ្ញុំបានជួយសង្គ្រោះនោះ។ ទាំងពីរនាក់ម្ដាយកូនរត់ទៅឱបអ្នកជំងឺ ដែលទើបតែដឹងខ្លួន ទាំងទឹកភ្នែកហូរសស្រាក់។ ខ្ញុំខ្លោចចិត្តអាណិតពួកគេ រួចហូរទឹកភ្នែករកទប់មិនឈ្នះ។ ទាំងបីនាក់បែរមុខមកខ្ញុំ ហើយសំពះអរគុណខ្ញុំ ទុកខ្ញុំដូចជាព្រះ។

ខ្ញុំប្រាប់ពួកគេវិញថា "គឺខ្ញុំវិញទេ ដែលត្រូវអរគុណអ្នកទាំងបី!"

គ្មានអ្វីរីករាយជាងបានធ្វើអំពើល្អទេ ហើយគ្មានអ្វីត្រេកអរជាងការភ្ញាក់រឭកឡើយ។ ធ្វើល្អពិតជាបានល្អមែន! បើក្មេងស្រីនោះមិនយកកាបូបលុយមកឱ្យខ្ញុំវិញ នាងប្រហែលជាត្រូវឃ្លាតពីឪពុកនាងជារៀងរហូត...។ តែងនៅថ្ងៃទី៥ មិថុនា ២០០៨ (ចប់)

# គោរពជូនកម្មវិធីកូនខ្មែរពិត

ជម្រាបសួរបងសុធានី បងប៊ុណ្ណា បងស្រីនាយិកា និងប្រិយមិត្តអ្នកស្តាប់កម្មវិធីកូនខ្មែរពិត ដោយក្តីគោរព និងក្តីនឹករឭក។ ខ្ញុំបាទគិតជាយូរមកហើយ ថាតើគួរផ្ញើអត្ថបទរឿងខ្លីជូនកម្មវិធីឬក៏អត់? បងសុធានីធ្លាប់មានប្រសាសន៍ថា កម្មវិធីចង់ឱ្យមានលក្ខណៈសម្បូរបែប ហើយកម្មវិធីយើងទៀតសោតក៏បានលើកស្ទួយផ្នែកអក្សរសិល្បល័កំណាព្យរួចទៅហើយ។ ហេតុនេះតើមានមូលហេតុអ្វីដែលខ្ញុំមិនអាចផ្ញើរឿងខ្លីជូនកម្មវិធីបាន? ខ្ញុំបាទគិតទៀតថា តើសមឬទេបើខ្ញុំចង់ជម្រាបប្រិយមិត្តលោកអ្នកស្តាប់ ដើម្បីសុំជំនួយសម្រាប់ក្រុមខ្ញុំបាទ។

ឧត្តមគតិអាណិតស្រលាញ់ជាតិរបស់លោកអ្នក ខ្ញុំបាទតែងស្តាប់ដោយក្តីរំភើប។ លោកអ្នកតែងតែមានអារម្មណ៍ចង់ជួយក្មេងកំព្រា ក៏ដូចជាជួយអប់រំសីលធម៌ក្នុងសង្គមជាតិយើង។ ជាការពិតណាស់ ខ្ញុំតែងតែគិតថាលោកអ្នកគឺជាកូនខ្មែរពិត ដែលប្រាថ្នាជួយកូនខ្មែរដូចគ្នា និងសង្គមជាតិ។ ហេតុនេះទើបថ្ងៃនេះខ្ញុំសម្រេចចិត្តផ្ញើស្នាដៃរឿងខ្លីមួយជូនលោកអ្នកពិចារណា។

ខ្ញុំបាទឈ្មោះ សុខ ចាន់ផល ជាតំណាងក្រុមយុវអ្នកនិពន្ធខ្មែរ។ សមាជិកយើងគឺជាយុវជនក្មេងៗដែលស្រលាញ់អក្សរសាស្ត្រជាតិ និងមានឧត្តមគតិចូលរួមអប់រំសង្គមតាមរយៈការតែងនិពន្ធ។ ពួកខ្ញុំខ្លះជាអ្នកនិពន្ធរឿងខ្លី ខ្លះជាអ្នកនិពន្ធកំណាព្យ។ ក្រុមនេះបង្កើតតាំងពីឆ្នាំ២០០៦ ហើយក៏បានបង្កើតពាក្យស្លោកប្រចាំក្រុមថា "ដើម្បីប្រជាជនខ្មែរចូលចិត្តអានសៀវភៅ" និងបានបង្កើតស្នាដៃរួមគ្នាបានចំនួនមួយក្បាល។ ជាអកុសលពួកខ្ញុំមិនអាចស្វែងរកប្រាក់ ដើម្បីបោះពុម្ពផ្សាយស្នាដៃរបស់ខ្លួនឡើយ។

កន្លងមកសមាជិករបស់ក្រុមយើងក៏បានចូលរួមក្នុងកម្មវិធីកូនខ្មែរពិតដែរ ដូចជា ហួរ លីឃាង ជាសិស្សថ្នាក់ទី១២នៅវិទ្យាល័យសន្ធរមុខ និង កើយ ចិត្រា ជានិស្សិតឆ្នាំទីមួយ ត្រៀមប្រលងរៀនផ្នែកវេជ្ជសាស្ត្រ។ ហេតុផលដែលក្រុមខ្ញុំមិនរីកចម្រើន ព្រោះពួកខ្ញុំមិនសូវចេះទំនាក់ទំនង បើទោះជាដឹងថាមានមនុស្សជាច្រើនចង់ជួយពួកយើងក៏ដោយ។ ពោលគឺរូបខ្ញុំផ្ទាល់ មូលហេតុដែលក្លាយខ្លួនជាតំណាងក្រុមនោះ

ដោយសារខ្ញុំមិនដែលអវត្តមាន ឬមានចិត្តចង់ចាកចេញពីក្រុម ទើបទាំងអស់គ្នាជ្រើសខ្ញុំជាតំណាង។ ប៉ុន្តែខ្ញុំចេះត្រឹមតែសរសេរប៉ុណ្ណោះ មិនចេះស្វែងរកអ្នកឧបត្ថម្ភឱ្យក្រុមសោះ។

រឿងខ្លី "កាបូបលុយ" គឺជាស្នាដៃថ្មីរបស់ខ្ញុំ ក៏ដូចជាឧត្តមគតិរបស់ក្រុមខ្ញុំ។ ជឿជាក់ថា ក្រោយពីបានស្តាប់រឿងនេះ លោកអ្នកនឹងចូលរួមជួយឧបត្ថមដល់ក្រុមនិពន្ធយើងក្នុងការបោះពុម្ពផ្សាយ ដែលពួកយើងកំពុងជួយគ្នា បង្កើតស្នាដៃថ្មីមួយក្បាល ឱ្យស្របជាមួយគោលគំនិតនៃកម្មវិធីកូនខ្មែរពិត។ លោកអ្នកអាចចូលរួមជួយក្រុម "យុវអ្នកនិពន្ធខ្មែរ" តាមសទ្ធាជ្រះថ្លា ដើម្បីឱ្យយើងខ្ញុំអាចប្រគល់សៀវភៅមួយក្បាលជូនសង្គមជាតិយើង។

ជាចុងក្រោយខ្ញុំបាទសូមលំឱនកាយអរគុណទុកជាមុនដល់លោកអ្នក និងសូមអភ័យទោសចំពោះពាក្យសម្តីឆ្គាំឆ្គងទាំងអម្បាលម៉ាន។ ពាក្យគ្រប់ម៉ាត់ដែលខ្ញុំសរសេរគឺជាទឹកចិត្តញញៀតញញៀមរបស់ខ្ញុំ តែខ្ញុំត្រូវតែក្លាហាន ហ៊ានសង្ឃឹមដើម្បីអនាគតរបស់ក្រុមខ្ញុំ។ ខ្ញុំបាទក៏សូមអភ័យទោស បងសុធានី បើសិនខ្ញុំនិយាយអ្វីខុសដោយមិនដឹងខ្លួន និងសូមឱ្យបងជួយឱ្យដំបូន្មានដល់ខ្ញុំផង។ ដោយឡែកក៏សូមអភ័យទោសចំពោះអត្ថន័យរឿងខ្លី ព្រោះបងគឺជាវេជ្ជបណ្ឌិត បងប៉ុណ្ណាក៏ធ្លាប់រៀនពេទ្យ ដែលចួននឹងតួអង្គក្នុងរឿងគឺជាគ្រូពេទ្យដែរ។ ពាក្យពេចន៍ដែលខ្ញុំប្រើប្រាកដជាឆ្គងដោយអន្លើ ដោយសារខ្ញុំពុំបានប្រឹក្សាជាមួយគ្រូពេទ្យឡើយ ហេតុនេះសង្ឃឹមថា បងសុធានីនឹងទូន្មានខ្ញុំ។ម្យ៉ាងក៏សូមអភ័យទោសពីលោកអ្នកជាគ្រូពេទ្យទាំងឡាយ ប្រសិនបើរឿងនេះមាននិយាយលើសលស់ពីតួនាទីរបស់លោកគ្រូអ្នកគ្រូ។

ភ្នំពេញ ថ្ងៃទី៧ មិថុនា ២០០៨

**តំណាង ក្រុមយុវអ្នកនិពន្ធខ្មែរ**

**សុខ ចាន់ផល**

ទូរស័ព្ទ ០៩២ ៤៨ ២៥ ៧៨